ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល
សភាផ្នែករដ្ឋប្បវេណី

សំណុំរឿងរដ្ឋប្បវេណី
លេខ : ៤៤៥
ចុះថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ២០០០

សាលដីកា
លេខ : ១១៨
ចុះថ្ងៃទី ២៣ ខែឧសភា ឆ្នាំ ២០០២

តាងនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ២៣ ខែឧសភា ឆ្នាំ ២០០២ ដោយមានសមាសភាពដូចតទៅ :

១-ឯកឧត្តម ឌិត មុន្ទី ប្រធានក្រុមប្រឹក្សាជំនុំជំរះ
២-លោក វៀល មួន ចៅក្រម
៣-លោក ឈឹម ស៊ីផល ចៅក្រម
៤-លោក ប្រាក់ គីមសាន ចៅក្រមរបាយការណ៍
៥-លោក ស៊ិន គីម ចៅក្រម
ក្រឡាបញ្ជី លោកស្រី ទី រ៉ាវី

តំណាងមហាអយ្យការ លោក ឈួន ចាន់ថា ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះបកស្រាយសាលដីការដ្ឋប្បវេណីលេខ ៧៨ ចុះថ្ងៃទី ២៤.៥.២០០១ របស់តុលាការកំពូល តាម លិខិតស្នើសុំលេខ ២៦១ព្រទ ៩៤០១-២០០១ ចុះថ្ងៃទី ២៩.៨.២០០១ របស់ព្រះរាជអាជ្ញា អមតុលាការក្រុងភ្នំពេញ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ ទេង ពន្លក ភេទស្រី អាយុ ៣១ឆ្នាំ ជាតិខ្មែរ របររកស៊ី បុគ្គលិកក្រសួងប្រៃសណីយ៍ ទីលំនៅសព្វថ្ងៃផ្ទះលេខ ១អឺ០ ផ្លូវ ២៥៦ ក្រុម៣០ សង្កាត់ទឹកល្អក់ ១ ខណ្ឌទួលគោក ក្រុងភ្នំពេញ ។

ឈ្មោះ ម៉ី ណារ៉ាត ភេទប្រុស អាយុ ៥០ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃ ផ្ទះលេខ ៣៥ អឺ០ សង្កាត់ផ្សារចាស់ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។ ទទួលសិទ្ធិពីឈ្មោះស៊ុយ តិក ទេង ។

និង ចុងបណ្តឹងសាទុក្ខឈ្មោះ ឡុក គីម ភេទស្រី អាយុ៤២ឆ្នាំ ជាតិខ្មែរ របររកស៊ី បុគ្គលិកវិទ្យាស្ថានសង្គម ទីលំនៅសព្វថ្ងៃផ្ទះលេខ ១អឺ០ ផ្លូវលេខ ២៥៦ ក្រុម៣០ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោកក្រុងភ្នំពេញ ។ ដែលមានឈ្មោះ ជូ ចាន់ធីរ៉ា ជាមេធាវី ។

កម្មវត្ថុបណ្តឹង : ប្តឹងទាមទារផ្ទះ និង ដីឡូតិ៍

បានឃើញបណ្តឹងសាទុក្ខលេខ ៣៨៧ ចុះថ្ងៃទី ២២.៩.២០០០ របស់ឈ្មោះ

ស៊ុយ តឹកហេង និង ឈ្មោះ ហេង ពន្លក ប្តឹងមិនសុខចិត្តពីសាលដីកាលេខ ៦៩ក ចុះថ្ងៃទី០១.៨.២០០០ របស់សាលាឧទ្ធរណ៍ លើចំនុច នៃ សេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៤៤៥ ចុះថ្ងៃទី ១៧.១១.២០០០ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ ឡុក គីម ប្តឹងទាមទារផ្ទះ និង ដីឡូតិ៍ ពីឈ្មោះ ហេង ពន្លក ដោយអាងហេតុថា ផ្ទះលេខ ១អ៊ី០ ផ្លូវ២៦៥ បងប្អូនខ្លួន និង ខ្លួន ចូលមកស្នាក់នៅតាំងពីឆ្នាំ ៧៩ ក្រោយមកខ្លួនបានហៅ ហេង ពន្លក មកស្នាក់នៅ ព្រមទាំង បងប្អូនមួយចំនួនទៀត បន្ទាប់មកអ្នកទាំងនោះមិនព្រមចុះចេញ ក៏កើតមានរឿងវិវាទរហូត ដល់បងស្រីខ្លួនឈ្មោះ ឡុក គីមសេង ស្លាប់បាត់ទៅ ។ ក្រោយមកខ្លួនក៏បន្តវិវាទនេះ ដោយខ្លួនសុខចិត្ត ដោះស្រាយគោលនយោបាយ មួយចំនួន ដល់គ្រួសារនេះ ប៉ុន្តែភាគីម្ខាងទៀត នៅតែមិនព្រម ។

បានឃើញសាល ក្រមលេខ១១ "ឃ" ចុះថ្ងៃទី ០៨.៤.៩៩ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ ៖

១-ទទួលពាក្យបណ្តឹងចុះថ្ងៃទី ២១.០២.៩៤ របស់ឈ្មោះ ឡុក គីម ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-ចែងចែកផ្ទះលេខ ១អ៊ី០ អ៊ី១ ផ្លូវលេខ ២៦៥ ក្រុម៣០ សង្កាត់ទឹកល្អក់១ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ដោយប្រគល់បន្ទប់ និង ទីកន្លែងឈ្មោះ ហេង ពន្លក និង ឡុកគីម ធ្លាប់កាន់កាប់ កន្លងមក ប្រគល់អោយឈ្មោះនេះ កាន់កាប់ ថែរក្សា ជាកម្មសិទ្ធិតទៅតាម គំនូសប្លង់បង្ហាញ ចុះថ្ងៃទី ០៧.១០.១៩៩២ របស់ការិយាល័យ ភូមិបាល ខ័ណ្ឌទួលគោក ចំពោះ ផ្លូវដើរ និង ទីធ្លាក្នុងបរិវេណផ្ទះ និង ដី នេះ ទុកជាសម្បត្តិរួម របស់គូភាគី ចំពោះផ្ទៃគ្រ និង បន្ទប់ ដែល ឡុក គីម ធ្លាប់កាន់កាប់ នៅជាន់ទី១ ត្រូវប្តូរមកជាន់ ផ្ទាល់ដី គឺបន្ទប់ លេខ ៦ ជាបន្ទប់ដែលគ្រួសារ ហេង ពន្លក ធ្លាប់កាន់កាប់ ។

៣-ចំពោះដីឡូតិ៍ខាងក្រោយផ្ទះ ត្រូវចែងចែកជាពីរចំណែកស្មើគ្នា ដោយ ហេង ពន្លក ពាក់កណ្តាល និង ឡុក គីម ពាក់កណ្តាល និង បង្គាប់អោយឈ្មោះ ឡុក គីម ជួយចេញថ្លៃចាកដី ចំនួន ៥០០ ដុល្លាអាមេរិក "ប្រាំរយដុល្លាអាមេរិក" ទៅ ហេង ពន្លកវិញ ។

៤-ចំពោះដីឡូតិ៍ចំហៀងផ្ទះ ស្ថិតនៅខាងជើងផ្ទះ ដែលមានដំណាំរួចហើយ និង ដំណាថ្មី ត្រូវប្រគល់ទៅអោយឈ្មោះ ហេង ពន្លក ជាកម្មសិទ្ធិ តទៅ ។

៥-បង្គាប់អោយឈ្មោះ ឡុក គីម បង់ប្រាក់ប្រដាប់ក្តី គឺ ពន្ធចុះបញ្ជីក្តី និង ពន្ធថ្លឹង ១.៨០០៛ រង្វាន់ក្រឡាបញ្ជីកាត់ហ៊ីបប្រាក់ ២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ ៥.០០០៛ សរុប ៧.០០០៛ ប្រាក់នេះត្រូវបានកាត់យកពីប្រាក់ ៧.០០០៛ ដែលដើមចោទ ឈ្មោះ

ឡុក គីម បានបង់ថ្លៃចុកដារស្រេច ។ កាលបើប្តឹងបណ្តឹងឧទ្ធរណ៍ បង្គាប់អោយឈ្មោះ ហេង ពន្លក បង់ប្រាក់ ៧.០០០៛ អោយទៅឈ្មោះ ឡុក គីម វិញ ព្រមទាំងបង់ពន្ធលមាមាត្រ មួយភាគរយ នៃ ទឹកប្រាក់សរុប ។

៦-សាលាក្រមនេះ ជំនុំជំរះ ជាសាធារណៈ ចំពោះមុខគូក្តី សំរេចបើកផ្លូវបណ្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍ របស់ឈ្មោះ ខាត់ សួយ ចុះថ្ងៃទី ១២.៤.៩៩ និង បណ្តឹងឧទ្ធរណ៍របស់ឈ្មោះ ស៊ុយ តឹកហេង និង ឈ្មោះ ហេង ពន្លក ចុះថ្ងៃទី ១៧.៥.៩៩ ប្តឹងមិនសុខចិត្ត លើសេចក្តីសំរេច នៃ សាលាក្រមទាំងមូល ។

បានឃើញសាលដីការបស់សាលាឧទ្ធរណ៍លេខ ៥៧៩ ចុះថ្ងៃទី ១៩.៨.៩៩ ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ :

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១២.៤.៩៩ របស់ឈ្មោះ ខាត់ សួយ " តំណាងអោយ ឈ្មោះ ឡុក គីម និង ពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៧.៥.៩៩ របស់ឈ្មោះ ហេង ពន្លក និង ឈ្មោះ ស៊ុយ តឹមហេង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

២-តំកល់សាលាក្រមរដ្ឋប្បវេណីលេខ ១១ "ឃ" ចុះថ្ងៃទី ០៨.៤.៩៩ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការពេញទាំងមូល លើកលែងតែចំនុចទី៣ នៃ សេចក្តីសំរេចបន្ថែម ពាក្យថា ដើមបណ្តឹងឧទ្ធរណ៍ឈ្មោះ ឡុក គីម យកចំណែកខាងជើង ចំណែកដើមបណ្តឹងឧទ្ធរណ៍ឈ្មោះ ហេង ពន្លក យកចំណែកខាងត្បូង ។

៣-រឹបអូសប្រាក់ប្រដាបក្តី ដាក់សាលាឧទ្ធរណ៍ចំនួន ១៣.០០០៛ ដែលដើមបណ្តឹងឧទ្ធរណ៍បានបង់រួចហើយគឺ ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ឹង ចំនួន ២.៥៥០៛ រង្វាន់ក្រឡាបញ្ជីកានពីបប្រាក់ចំនួន ៤៥០៛ រង្វាន់អ្នកប្រគល់ដីកានោះ ចំនួន ៥.០០០៛ និង ចំណាយលើ អាជ្ញាធរតុលាការ ចំនួន ៥.០០០៛ ។

៤-សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខ ខាត់ សួយ និង កំបាំងមុខ ហេង ពន្លក ។ បើកផ្លូវប្តឹងទាស់ និង សាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់របស់ឈ្មោះ ស៊ុយ តឹកហេង និង ឈ្មោះ ហេង ពន្លក ចុះថ្ងៃទី ០៦.៩.៩៩ ប្តឹងមិនសុខចិត្ត លើសេចក្តីសំរេច នៃ សាលដីកាទាំងមូល ។

បានឃើញសាលដីការបស់សាលាឧទ្ធរណ៍លេខ ៦៩ "ក" ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០០ ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ :

១-ទទួលសេចក្តីសុំប្តឹងទាស់ ចុះថ្ងៃទី ០៦.៩.៩៩ របស់ឈ្មោះ ស៊ុយតឹកហេង និង ហេង ពន្លក ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីកំពាំងមុខលេខ ៥៧៩ ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការ តែកែប្រែដូចតទៅ ៖

-ផ្ទះលេខ ១អឺ០ បន្ទប់ "១.២.៣.៤" ក្នុងគំនូសប្លង់ ផែនទី បង្គោលបង្ហាញ ចុះថ្ងៃទី ០៧.១០.៩២ ប្រគល់អោយនាង ឡុក គីម ។ បន្ទប់លេខ ១អឺ១ និង ឡូតិ៍ដែលលយផ្ទះលេខ ១អឺ០ "ក្រោយរង្វង់ផ្ទះ" ត្រូវប្រគល់ឱ្យនាង ហេង ពន្លក ។

-ឯដីឡូតិ៍ដែលត្រូវបែងចែកគ្នាជាពីរនោះ ត្រូវគិតពីត្បូងមកជើង អោយមានផ្លូវចេញដល់ថ្នល់ធំ "ថ្នល់ទៅពោធិចិនតុង" ដូចគ្នា ។

៣-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខគូក្តី បើកផ្លូវប្តឹងសាទុក្ខ ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខ របស់ឈ្មោះ ស៊ុយ គឹកហេង និង ឈ្មោះ ហេង ពន្លក ចុះថ្ងៃទី ២២.៩.២០០០ ប្តឹងមិនសុខចិត្តលើសេចក្តីសំរេច នៃ សាលដីកាទាំងមូល ។

បានឃើញសាលដីការបស់ តុលាការកំពូល លេខ ៧៨ ចុះថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០០១ ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ ៖

១-ទទួលបណ្តឹងសាទុក្ខលេខ ៣៨៧ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០០០ របស់អ្នកស្រី ហេង ពន្លក និង លោក ស៊ុយ គឹកហេង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោល ដោយខុស នឹង គតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ ៦៩ "ក" ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-ទំរូវប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០៛ ដែលអ្នកស្រី ហេងពន្លក បានបង់រួចហើយ គឺ ៖

-ពន្ធចុះបញ្ជីក្តី និង ពន្ធប្តឹង ចំនួន ៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ .

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះ ចំនួន ១៥.០០០៛ សរុប ១៩.០០០៛ ។

បង្គាប់អោយអ្នកស្រី ឡុក គីម បង់ពន្ធលមាមាត្រ មួយភាគរយ លើទឹកប្រាក់ ៥០០ដុល្លាអាមេរិក ដែលត្រូវប្រគល់ទៅអោយលោក ស៊ុយ គឹកហេង ។

៤-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០០១ ។

បានឃើញលិខិតលេខ ២៦១ ព្រទ ៩៤០១-២០០១ ចុះថ្ងៃទី ២៩.៨.២០០១ របស់ព្រះរាជអាជ្ញា អម តុលាការក្រុងភ្នំពេញ ធ្វើឡើងត្រឹមត្រូវតាមច្បាប់ ។

បានស្តាប់របាយការណ៍បន្ថែម របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ អម តុលាការកំពូល ថា :

-បណ្តឹងសាទុក្ខរបស់ដើមចោទ ធ្វើឡើងក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិនិត្យ ពិចារណា ។ សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិនិត្យ និង សំរេច ។

បានស្តាប់ចម្លើយ របស់ឈ្មោះ ឡុក គីម ជាចុងបណ្តឹងសាទុក្ខ នៅពេលជំនុំជំរះ ឆ្លើយថា :

- តុលាការសំរេច ផ្ទះជាន់ក្រោមឱ្យខ្លួន ដល់ដីអោយគេ ធ្វើអោយខ្លួនគ្មានផ្លូវដើរ ។ ខ្លួនសុំយកដី ចំណែកខាងកើត ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ម៉ី ណារ៉ាត តំណាងអោយឈ្មោះ ស៊ុយ គឹកហេង និង ហេង ពន្លក ជាម្ចាស់បណ្តឹងសាទុក្ខ នៅពេលជំនុំជំរះឆ្លើយថា :

-តាមការបញ្ជីរបស់សូរិយោដីថា ដីក្រៅរបងផ្ទះ គឺជាដី ជាប់ជញ្ជាំងផ្ទះ សេចក្តីសំរេចរបស់តុលាការមិនច្បាស់លាស់ មិន ដឹងថា តើខ្លួនត្រូវបានខាងកើត ឬ ខាងលិច ខ្លួនសុខចិត្តធ្វើសប្បទាន អោយដើមចោទ បើកឲ្យមានផ្លូវត្រង់ គឺទទឹងមានប្រវែង ១ម៉ែត្រ ៥០ និង ធ្វើរបងជូនទៀត ដើម្បីការពារសុវត្ថិភាព ខ្លួនសុំយកដីចំណែកខាងកើត ព្រោះដំណាំទាំងនេះ ជារបស់ ស៊ុយ គឹកហេង ជាអ្នកដាំ និង អាស្រ័យផល ។ សុំតម្កល់សាលដីការបស់ តុលាការកំពូលទាំងមូល ។

មេធាវី របស់ដើមចោទធ្វើសេចក្តីសន្និដ្ឋាន ថា :

-ការសំរេចរបស់តុលាការមិនច្បាស់លាស់ តើកូនក្តីខ្លួនត្រូវបានខាងណា ហើយដីក្រៅរបងផ្ទះ ត្រូវបានទៅភាគី ចុងចម្លើយ ធ្វើអោយកូនក្តីខ្លួន គ្មានផ្លូវដើរ ។

-សុំបែងចែកដីមុខផ្ទះ អោយមានភាពស្មើគ្នា និង ដាច់ស្រឡះពីគ្នា - សុំទ្វារច្រកកណ្តាល អោយកូនក្តីខ្លួន - សុំដីផ្នែកខាងកើត ព្រោះជាដីជាប់ផ្ទះកូនក្តីខ្លួន ។

-ក្រោយពីបានស្តាប់ របាយការណ៍បន្ថែម របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់ សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ ចំលើយ របស់គូភាគី និង សេចក្តីសន្និដ្ឋាន របស់មេធាវី របស់អ្នកស្រី ឡុក គីម

-ក្រោយពីបាន ពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

-យល់ឃើញថា លិខិតលេខ ២៦១ ព្រទ ៩៤០១-២០០១ ចុះថ្ងៃទី២៩.៨.២០០១

របស់ព្រះរាជអាជ្ញា អម តុលាការក្រុងភ្នំពេញ ធ្វើឡើងត្រឹមត្រូវតាមច្បាប់ តុលាការកំពូល អាចលើករឿងនេះ មកជំនុំជំរះ បកស្រាយ បាន ។

-យល់ឃើញថា ក្នុងការសំរេចសេចក្តី តុលាការថ្នាក់ក្រោម បានសំរេច តម្កល់ និង កែប្រែសាលក្រម និង សាលដីកា ជាបន្តបន្ទាប់ ដែលនាំអោយមានភាពមិនច្បាស់ ពុំអាចអនុវត្តបាន ដែលគប្បីតុលាការកំពូល កំណត់អោយបានច្បាស់ ។

-យល់ឃើញថា ដោយបន្ទប់ជាន់ផ្ទាល់ដីលេខ ១៦ ត្រូវបានតុលាការក្រុងភ្នំពេញ សំរេចប្រគល់អោយអ្នកស្រី ឡុក គីម កាន់កាប់ ហើយត្រូវបានសាលាឧទ្ធរណ៍ និង តុលាការកំពូល សំរេចតម្កល់ទុកជាបានការហើយនោះ តុលាការកំពូល គប្បីសំរេចបើកផ្លូវអោយអ្នកស្រី ឡុក គីម ប្រើប្រាស់ពីបន្ទប់នេះ មកដល់ផ្លូវលេខ ២៦១ ដើម្បីងាយស្រួលក្នុងការចេញចូល ។

-យល់ឃើញថា ដីឡូត៍លេខ ១២២ ដែលតុលាការសំរេចបែងចែក ជាពីរស្មើគ្នា ពីជើងមកត្បូងនោះ គប្បីកំណត់ តាមអាទិភាពជាក់ស្តែង នៃ ការកាន់កាប់ របស់គូភាគី ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តី ចំពោះមុខ គូក្តី

១-ទទួលលិខិតលេខ ២៦១ ព្រព ៩៤០១-២០០១ ចុះថ្ងៃទី ២៩.៨.២០០១ របស់ព្រះរាជអាជ្ញា អមតុលាការក្រុងភ្នំពេញ ទុកជាត្រឹមត្រូវតាមច្បាប់ ។

២-សំរេចអោយបើកផ្លូវ ទទឹងស្មើនឹង ទទឹងខាងកើត នៃ បន្ទប់ លេខ១៦អឺ០ មកកាន់ផ្លូវលេខ ២៦១ អោយអ្នកស្រី ឡុក គីម ប្រើប្រាស់តទៅ ។

៣-បែងចែកដីឡូត៍លេខ ១២២ ជាពីរចំណែក ស្មើគ្នា ពីជើងមកត្បូង ដោយប្រគល់ដីផ្នែកខាងលិច អោយអ្នកស្រី ឡុក គីម កាន់កាប់ និង ផ្នែកខាងកើត អោយអ្នកស្រី ទេង ពន្លក កាន់កាប់តទៅ ។

៤-សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០២ ។